# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាបុណ្យចូលឆ្នាំវៀតណាមនៅព្រះសហគមន៍សន្តហ្វ្រង់សាវីយេ
# ចំប៉ា ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២០
# យកបុព្វបុរសជាគំរូដើម្បីដឹកនាំជីវិតយើង

**អត្ថបទទី១៖ អេសាយ ៨,២៣ខ-៩,៣**

ប្រជាជនដែលដើរក្នុងភាពងងឹត បានឃើញពន្លឺមួយដ៏ចិញ្ចែងចិញ្ចាច មានពន្លឺមួយលេចឡើងបំភ្លឺអស់អ្នក ដែលរស់នៅក្រោមអំណាចនៃសេចក្ដីស្លាប់។ អស ៩,១

**អត្ថបទទី២៖ កូរិនថូសទី១ ១,១០-១៣.១៧**

ព្រះគ្រីស្ដពុំបានចាត់ខ្ញុំឲ្យមកធ្វើពិធីជ្រមុជទឹកឡើយ គឺទ្រង់ចាត់ខ្ញុំឲ្យមកផ្សព្វផ្សាយដំណឹងល្អវិញ។ ១ករ ១,១៧ក

**ដំណឹងល្អ៖ ម៉ាថាយ ៤,១២-២៣**

អ្នកទាំងពីរចាកចោលទូក ចាកចោលឪពុកភ្លាម រួចដើរតាមព្រះយេស៊ូទៅ។ មថ ៤,២២

បងប្អូនជាទីស្រឡាញ់!

យើងអរព្រះគុណព្រះជាម្ចាស់សម្រាប់ឆ្នាំថ្មី ណែនាំឲ្យយើងជាគ្រីស្ដបរិស័ទទទួលព្រះពរដ៏ពេញលក្ខណៈពីព្រះជាម្ចាស់ ដែលជាព្រះបិតារបស់យើង។ យើងចូលនៅក្នុងឆ្នាំថ្មីនេះ មិនភ័យខ្លាច មិនព្រួយបារម្ភ មិនបាត់សេចក្ដីសង្ឃឹមទេ ដោយសារព្រះជាម្ចាស់ប្រទានព្រះពរឲ្យយើង។ ព្រះជាម្ចាស់មិនមែនផ្សេងពីជីវិតរបស់យើង ព្រះជាម្ចាស់ភ្ជាប់នឹងជីវិតរបស់យើងប្រចាំ។ ថ្ងៃនេះយើងពោរពេញដោយកម្លាំងកាយកម្លាំងចិត្ត ដោយសារយើងមានព្រះជាម្ចាស់ដែលគង់នៅ ឲ្យយើងធ្វើជាសាវ័ករបស់ព្រះគ្រីស្ដ ដែលជាប់ឫសនឹងជីវិតដែលយើងបានទទួលពីព្រះអង្គ។ ជីវិតរបស់យើង ដល់ពេលវេលាចេញផ្កាដើម្បីអរព្រះគុណព្រះជាម្ចាស់ ដែលជាផ្កាពិតៗដោយសារជីវិតរបស់យើងជាជីវិតពិត។

ជីវិតយើងដូចដើមឈើពិតៗ ដែលចេញផ្កាដល់ពេលវេលា ចេញស្លឹកដល់ពេលវេលា ដែលមានផ្កាមួយចំនួនកំពុងរុះរោយ មានមួយចំនួនកំពុងរីកយ៉ាងស្អាត និងមានមួយចំនួនមិនទាន់ចេញផ្កាទេ។ ជីវិតពិតរបស់យើងជាគ្រីស្ដបរិស័ទ អាចទៅមុខបានទោះបីយើងមានទុក្ខលំបាកក៏ដោយ ទោះបីយើងឈឺចាប់ក៏ដោយ យើងដឹងថាយើងចាក់គ្រឹះនៅក្នុងទឹកដីរបស់ព្រះជាម្ចាស់។ ទឹកដីរបស់ព្រះជាម្ចាស់ ណែនាំឲ្យយើងលូតលាស់ពីមួយថ្ងៃទៅមួយថ្ងៃ នៅក្នុងគ្រាសប្បាយក៏ដោយ នៅគ្រាអាសន្នក៏ដោយ យើងមានព្រះជាម្ចាស់ដែលគង់នៅ។ នៅពេលយើងចូលអភិបូជាក្នុងថ្ងៃចូលឆ្នាំថ្មី យើងត្រូវការនឹកឃើញថាព្រះជាម្ចាស់ជាជីវិតរបស់យើង ព្រះជាម្ចាស់ប្រទានព្រះពរឲ្យយើងរៀងៗខ្លួន ដើម្បីឲ្យពេញមួយឆ្នាំខាងមុខដែលជួនកាលយើងជាផ្កា

ស្អាត ជួនកាលយើងជាផ្កាដែលរុះរោយ ជួនកាលយើងជាផ្កាក្រពុំ យើងដឹងថាព្រះជាម្ចាស់គង់នៅ ដើម្បីធ្វើដំណើរជាមួយយើងតទៅទៀត។

ឆ្នាំនេះជាឆ្នាំកណ្តុរ សត្វកណ្តុរជាសត្វឧស្សាហ៍ណាស់ដើម្បីរកស៊ីចិញ្ចឹមគ្រួសារ ដូច្នេះឲ្យយើងយកចិត្តទុកដាក់ធ្វើការរកស៊ី និងថែរក្សាគ្រួសាររបស់យើងដូចសត្វកណ្តុរ។ ថ្ងៃនេះ ដែលយើងជាមហាគ្រួសារមួយយើងដឹងថាព្រះជាម្ចាស់គង់នៅ ដើម្បីឲ្យឆ្នាំថ្មីនេះយើងយកចិត្តទុកដាក់ជាមួយគ្រួសារ ឲ្យយើងចេះស្រឡាញ់ក្រុមគ្រួសាររបស់យើង និងឲ្យយើងចេះលើកលែងទោសឲ្យគ្នាទៅវិញទៅមក ដើម្បីទទួលសេចក្តីសុខដ៏ពិតប្រាកដ។ ប្រសិនបើយើងរស់នៅក្នុងគ្រួសារដ៏សុខសាន្តនេះ យើងដឹងថាសង្គមនិងព្រះសហគមន៍យើងពោរពេញដោយសេចក្តីសុខ។

ថ្ងៃនេះ យើងគោរពបុព្វបុរសរបស់យើង បុព្វបុរសដែលមានឈ្មោះល្បី ដែលមានចិត្តបរិសុទ្ធ ដែលមានចិត្តមេត្តាករុណា ដែលមានប្រាជ្ញាឈ្លាសវៃ ណែនាំឲ្យទៅជាកម្លាំងសម្រាប់យើងដោយយកធ្វើជាគំរូ។ យើងរស់នៅលើទឹកដីប្រទេសកម្ពុជា យើងមានវីរបុរសដែលខ្មែរគោរពគឺ ព្រះបាទជ័យវរ្ម័នទី៧ដែលជាស្តេចនៅក្នុងសម័យអង្គរព្រះអង្គបានសាងសង់ប្រាសាទបាយ័ន (អង្គរធំ)។ មូលហេតុដែលយើងគោរពព្រះបាទជ័យវរ្ម័នទី៧ ដោយសារព្រះអង្គជាស្តេចមួយអង្គដែលៈ

**ទី១** ណែនាំឲ្យជនជាតិខ្មែរ ស្រឡាញ់និងគោរពព្រះពុទ្ធ ដោយបានណែនាំឲ្យប្រជារាស្ត្រកម្ពុជាទៅជាប្រជារាស្ត្រតែមួយ មានសាសនាតែមួយ។

**ទី២** គាត់មិនមែនជាព្រះមហាក្សត្រដែលគង់នៅតែក្នុងព្រះរាជវាំង ព្រះអង្គបានចេញពីព្រះរាជវាំងដើម្បីទៅសួរសុខទុក្ខប្រជារាស្ត្រ ដើម្បីដឹងថាប្រជារាស្ត្រព្រះអង្គមានទុក្ខលំបាកអ្វីខ្លះមានបញ្ហាអ្វីខ្លះ។ ព្រះអង្គបានសាងសង់មណ្ឌលសុខភាព ជាង១០០កន្លែងនៅលើទឹកដីកម្ពុជាដើម្បីឲ្យអ្នកជំងឺមានកន្លែងព្យាបាលជំងឺ។ ព្រះអង្គក៏បានសាងសង់សាលាឆទាននៅតាមផ្លូវនានាដើម្បីឲ្យប្រជារាស្ត្រកម្ពុជាដែលធ្វើដំណើរទៅឆ្ងាយមានកន្លែងសម្រាក។ ព្រះបាទជ័យវរ្ម័នទី៧ព្រះអង្គបានចេញពីព្រះរាជវាំងដើម្បីទៅសួរសុខទុក្ខប្រជាជនព្រះអង្គ មានន័យថាព្រះអង្គមានព្រះហឫទ័យមេត្តាករុណា។ នេះជាមេរៀនមួយ សម្រាប់យើងនៅក្នុងឆ្នាំថ្មីនេះ ឲ្យយើងមានចិត្តមេត្តាករុណាជានិច្ច។

យើងជាបងប្រុសបងស្រី ជាលោកអភិបាល ជាលោកបូជាចារ្យ ជាគ្រីស្តបរិស័ទ យើងយកព្រះជាម្ចាស់ជាគំរូ យកព្រះយេស៊ូជាគំរូ យកបុព្វបុរសរបស់យើងជាគំរូ យកសន្តសន្តីជាគំរូ ដើម្បីណែនាំឲ្យសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ទៅដល់បងប្អូនរបស់យើង។ នៅក្នុងឆ្នាំថ្មីនេះ ឲ្យ

ដួងចិត្តរបស់យើង ឲ្យបេះដូងរបស់យើង ដូចជាព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់នៅលើផែនដីនេះ។ នៅសាលាក្តី នៅក្នុងភូមិក្តី នៅកន្លែងដែលយើងធ្វើការក្តី ឲ្យយើងចេះបើកភ្នែកដើម្បីយល់ដល់ទុក្ខលំបាករបស់បងប្អូន និងណែនាំឲ្យបងប្អូនអាចមានសេចក្តីសង្ឃឹមនិងកម្លាំងកាយកម្លាំងចិត្តថែមទៀត។ យើងត្រូវតែយកចិត្តទុកដាក់ ដោយមើលគំរូបុព្វបុរសរបស់យើង មើលគំរូជីដូនជីតារបស់យើងដែលបានតស៊ូ មើលគំរូសន្តសន្តីរបស់យើង មើលគំរូព្រះយេស៊ូផ្ទាល់ ដើម្បីឲ្យយើងរស់នៅក្នុងឆ្នាំថ្មីនេះប្រកបដោយសេចក្តីសុខ ក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ពិតៗ។ យើងដឹងថា ជីវិតរបស់យើងនឹងមានផ្កាតទៅទៀតលុះត្រាតែ យើងចាក់គ្រឹះនៅក្នុងការអធិដ្ឋាន នៅក្នុងអគ្គសញ្ញានានា នៅក្នុងការសូត្រផ្គាំ ដើម្បីជាប់ជាមួយព្រះយេស៊ូជានិច្ច។

ខ្ញុំសូមជូនពរ ឲ្យបងប្អូនទាំងអស់មានដោយសុខភាពល្អ សេចក្តីសុខ ធ្វើជាគ្រីស្តបរិស័ទដែលចេះស្រឡាញ់គ្នាទៅវិញទៅមកយ៉ាងពិតប្រាកដ នៅក្នុងព្រះអម្ចាស់យេស៊ូដែលយាងមកដើម្បីឲ្យយើងមានជីវិតដ៏បរិបូណ៌។ អាម៉ែន៕